**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៥៦ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- បានឃើញប្រកាសលេខ ៩៧០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

## សម្រេច

**ប្រការ ១.-**

អនុញ្ញាតឱ្យអគ្គនាយកដ្ឋានពន្ធដារ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

សេវាសាធារណៈដែលផ្តល់ដោយអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកដ្ឋានពន្ធដារត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវាក្នុងនោះរួមមាន ÷ តារាងកម្រងសេវាសាធារណៈ និងសំណុំឯកសារពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ។

អគ្គនាយកដ្ឋានពន្ធដារត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

**ប្រការ ៣.-**

អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចប្រមូលចំណូល កត់ត្រាតាមដានប្រាក់ចំណូល និងរៀបចំឯកសារសម្រាប់ការកត់ត្រាឆ្លុះបញ្ចាំងក្នុងកិច្ចប្រតិបត្តិការចំណូលថវិកាជាតិ។

**ប្រការ ៤.-**

រាល់ការប្រមូលចំណូលជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៥.-**

អគ្គនាយកដ្ឋានពន្ធដារត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៦.—**

អគ្គនាយកដ្ឋានពន្ធដារត្រូវធ្វើរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។ របាយការណ៍នេះ ត្រូវចម្លងជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ដើម្បីតាមដានការអនុវត្តចំណូល។

**ប្រការ ៧.—**

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសនេះ អាចកែប្រែបានតាមការចាំបាច់តាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៨.—**

ប្រកាសលេខ ៩៧០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.—**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត

«ដើម្បីជូនជ្រាប»

- ដូចប្រការ ៩ «ដើម្បីមុខការ»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធភ្ជាប់ទៅនឹងប្រកាសលេខ ១១៤៦ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១៥

## ស្ដីពីការផ្ដល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | សេវាចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស<br>- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អ.ត.ប)<br>- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ<br>- ប័ណ្ណពន្ធប៉ាតង់ | ៤០០ ០០០ រៀល | - ៧-១០ថ្ងៃ<br>(នៅរដ្ឋបាលសារពើពន្ធ)<br>- ១-៧ថ្ងៃ<br>(តាមរយៈប្រព័ន្ធអេឡិចត្រូនិច) | គ្មានកាលកំណត់<br>រហូតបិទសហគ្រាស |
| ២ | សេវាចុះបញ្ជីពន្ធដារតាមរបបម៉ៅការ<br>- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ<br>- ប័ណ្ណពន្ធប៉ាតង់ | ២០ ០០០ រៀល | | |
| ៣ | សេវាធ្វើបច្ចុប្បន្នភាពព័ត៌មានតាមរបបស្វ័យប្រកាស<br>- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អ.ត.ប)<br>- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ<br>- ប័ណ្ណពន្ធប៉ាតង់ | ២០០ ០០០ រៀល | | |
| ៤ | សេវាធ្វើបច្ចុប្បន្នភាពព័ត៌មានតាមរបបម៉ៅការ<br>- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ<br>- ប័ណ្ណពន្ធប៉ាតង់ | ១០ ០០០ រៀល | | |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៥ | លក់តែមប្រើអាករ ÷<br>-បិទលើកញ្ចប់បារី (ក្នុងមួយសន្លឹក)<br>-បិទលើកេសស្រា ស្រាបៀរ ឬភេសជ្ជៈគ្មានជាតិសុរា (ក្នុងមួយសន្លឹក) | <br>៥០ រៀល<br>១០០ រៀល | ភ្លាមៗ | ប្រើប្រាស់តែមួយដង |
| ៦ | សេវាទទួលលិខិតប្រកាសពន្ធប្រចាំខែក្នុងរបបស្វ័យប្រកាស<br>- ពន្ធលើប្រាក់បៀវត្ស<br>- ពន្ធកាត់ទុក<br>- អាករលើតម្លៃបន្ថែម<br>- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ/អាករពិសេសលើទំនិញ និងសេវាមួយចំនួន/អាករលើការស្នាក់នៅ/អាករសម្រាប់បំភ្លឺសាធារណៈ/ និងពន្ធអាករផ្សេងៗទៀត | 0 រៀល | ១ថ្ងៃ (បើបង់ប្រាក់នៅធនាគាររួច) | ១ខែ |
| ៧ | សេវាទទួលលិខិតប្រកាសពន្ធប្រចាំឆ្នាំក្នុងរបបស្វ័យប្រកាស<br>- ពន្ធលើប្រាក់ចំណេញ<br>- ពន្ធប៉ាតង់ | 0 រៀល | ១ថ្ងៃ (បើបង់ប្រាក់នៅធនាគាររួច)<br>១ថ្ងៃ<br>៣-៧ថ្ងៃ | ១ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៨ | សេវាទទួលលិខិតប្រកាសពន្ធក្នុងរបបម៉ៅការ<br>- អាករលើផលរបរ<br>- ពន្ធលើប្រាក់ចំណេញ<br>- ពន្ធប៉ាតង់ | 0 រៀល | ១ថ្ងៃ | ៣-៦-១២ខែ |
| ៩ | ពន្ធលើអចលនទ្រព្យ | 0 រៀល | ភ្លាមៗ | ១ឆ្នាំ |
| ១០ | ពន្ធលើឈ្នួលផ្ទះ និងដី | 0 រៀល | ភ្លាមៗ | តាមកិច្ចសន្យា |
| ១១ | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 0 រៀល | ១-២ថ្ងៃ | ១ឆ្នាំ |
| ១២ | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 0 រៀល | ភ្លាមៗ | ១ឆ្នាំ |
| ១៣ | ពន្ធតែមប្រិ៍ (ផ្លាកផ្សាយពាណិជ្ជកម្ម/ ផ្លាកយីហោ) | 0 រៀល | ភ្លាមៗ | ១ឆ្នាំ |
| ១៤ | ពន្ធសត្តឃាត | 0 រៀល | ភ្លាមៗ | ១ខែ |
| ១៥ | អាករលើការស្នាក់នៅ «របបម៉ៅការ» | 0 រៀល | ភ្លាមៗ | ១ខែ |
| ១៦ | អាករបំភ្លឺសាធារណៈ «របបម៉ៅការ» | 0 រៀល | ភ្លាមៗ | ១ខែ |
| ១៧ | ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ចំពោះ<br>- ផ្ទេរអចលនទ្រព្យមិនស្ថិតក្រោមរូបភាពជាប្រទានកម្ម ឬជាសន្តតិកម្ម<br>- ផ្ទេរអចលនទ្រព្យដែលមានតម្លៃចាប់ពី ១០០លានរៀល ឬ<br>មានប្រាក់ពន្ធចាប់ពី ៤លានរៀល ឡើងទៅ | ៤០០ ០០០ រៀល | ៤-៨ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៨ | ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ចំពោះ<br>- ផ្ទេរអចលនទ្រព្យក្រោមរូបភាពជាប្រទានកម្ម ឬជាសន្តតិកម្ម<br>- ផ្ទេរអចលនទ្រព្យដែលមានតម្លៃក្រោម ១០០លានរៀល ឬ មានប្រាក់ពន្ធក្រោម ៤លានរៀល | ០ រៀល | ៤-៨ថ្ងៃ | |
| ១៩ | ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬយានជំនិះគ្រប់ប្រភេទ | ០ រៀល | ២-៥ថ្ងៃ | |
| ២០ | ពន្ធប្រថាប់ត្រាលើការផ្ទេរភាគហ៊ុនរបស់ក្រុមហ៊ុន | ០ រៀល | ៤-៨ថ្ងៃ | |
| ២១ | កិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ | ០ រៀល | ១-៣ថ្ងៃ | |
| ២២ | ពន្ធប្រថាប់ត្រាលើឯកសារមានលក្ខណៈគតិយុត្តិ<br>- លិខិតស្តីពីការបង្កើតក្រុមហ៊ុន<br>- លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា<br>- និងលិខិតស្តីពីការបិទក្រុមហ៊ុន | ០ រៀល | ១-៣ថ្ងៃ<br>(បន្ទាប់ពីលទ្ធផលសវនកម្ម) | |
| ២៣ | សេវាបញ្ជាក់កាតព្វកិច្ចសារពើពន្ធ | ០ រៀល | ៤-៨ថ្ងៃ<br>(បន្ទាប់ពីលទ្ធផលសវនកម្ម) | |
| ២៤ | សេវាប្រឹក្សាអំពីនីតិវិធីសារពើពន្ធ | ០ រៀល | ភ្លាមៗ | |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៥ | សេវាផ្តល់ប័ណ្ណបង់ពន្ធ ÷<br>- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ<br>- ពន្ធលើអចលនទ្រព្យ | <br>៥ ០០០ រៀល<br>៥ ០០០ រៀល | ក្នុងពេលប្រកាសបង់ពន្ធ | អចិន្ត្រៃយ៍ |
| ២៦ | សេវាបង់ថ្លៃសិក្សាវគ្គភ្នាក់ងារសេវាកម្មពន្ធដារនៅសាលាជាតិពន្ធដារ | ១ ០០០ ០០០ រៀល | ពេលដាក់ពាក្យ | ប្រើប្រាស់តែមួយដង |
| ២៧ | សេវាផ្តល់សិទ្ធិប្រឡងនៅសាលាជាតិពន្ធដារ (សិក្ខាកាមឆ្លងកាត់វគ្គបណ្តុះបណ្តាលនៅសាលាជាតិពន្ធដារ)<br>- ប្រឡងលើកទី១ និងទី២<br>- ប្រឡងចាប់ពីលើកទី៣ ឡើងទៅ | <br>៨០ ០០០ រៀល<br>១០០ ០០០ រៀល | ពេលដាក់ពាក្យ | ប្រើប្រាស់តែមួយដង |
| ២៨ | សេវាផ្តល់សិទ្ធិប្រឡងនៅសាលាជាតិពន្ធដារ (សិក្ខាកាមមិនបានឆ្លងវគ្គបណ្តុះបណ្តាលនៅសាលាជាតិពន្ធដារ) | ៥០០ ០០០ រៀល | ពេលដាក់ពាក្យ | ប្រើប្រាស់តែមួយដង |

<u>កំណត់សម្គាល់ :</u> ចំពោះសេវា "លក់តែមប្រើអាករ សម្រាប់បិទលើកញ្ចប់បារី" ដែលមានតម្លៃ ៥០ រៀល ក្នុងមួយសន្លឹក នឹងចាប់អនុវត្តនៅពេលដែលសន្លឹកតែមប្រើប្រភេទថ្មីនេះ ត្រូវបានបោះពុម្ពរួច និងមានការសម្រេចឱ្យប្រើប្រាស់ជាផ្លូវការ។ ក្នុងករណីមិនទាន់មានការសម្រេចឱ្យប្រើប្រាស់សន្លឹកតែមប្រើប្រភេទថ្មីទេនោះ ត្រូវបន្តប្រើប្រាស់សន្លឹកតែមប្រើប្រភេទចាស់ ដែលមានតម្លៃ ៤,២ រៀល ក្នុងមួយសន្លឹក។